# រឿងក្តីទាមទារ[1]ឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ

[1] ការទាមទាររបស់ X គឺជាការទាមទារនូវការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ ហើយអ្នកដែលអនុវត្តនូវការចុះបញ្ជី គឺជារដ្ឋបាលសុរិយោដី (ប្រការ ៩០ នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី) មិនមែនជា Yទេ។ Y មានករណីយកិច្ចធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី (កថាខណ្ឌទី ១ ប្រការ ១០ នៃប្រកាសដដែល) ពោល គឺ Y ពុំមានករណីយកិច្ចលើសពីការបង្ហាញឆន្ទៈអំពីការដាក់ពាក្យសុំចុះបញ្ជីទេ ដូច្នេះហើយ ការទាមទារពី X ទៅ Y មិនមែនជាការទាមទារអំពី "ការចុះបញ្ជី" ទេ ប៉ុន្តែ គឺជាការទាមទារអំពី "នីតិវិធី" នៃការចុះបញ្ជីនោះ។

- ការអះអាងរបស់ X

នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ ខ្ញុំបានទិញដី (ដីលំនៅដ្ឋាន ទំហំ ១២០ $m^2$ ក្បាលដីលេខ ១៣០៦ ដែលមានទីតាំងស្ថិតនៅផ្លូវលេខ ១០២ ភូមិ ៣ សង្កាត់ ជ្រោយចង្វារ ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ) (តទៅនេះហៅថា " ដី L ") ដែលជាកម្មសិទ្ធិរបស់ Y នៅក្នុងតម្លៃ ២០០.០០០ (ពីរសែន) ដុល្លារអាមេរិក ពី Y (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ") ហើយបានធ្វើលិខិតយថាភូតនៅថ្ងៃនោះផងដែរ។ នៅពេលនោះ ខ្ញុំ និង Y បានព្រមព្រៀងគ្នាអំពីការបង់ប្រាក់កក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ហើយខ្ញុំបានប្រគល់ឲ្យ Y ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ នៅក្នុងកិច្ចសន្យានៃរឿងក្តីនេះ បានកំណត់ថា រយៈពេល១ខែក្រោយដែលត្រូវនឹងថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៨ Y ត្រូវប្រគល់ និង ធ្វើនីតិវិធីចុះបញ្ជីនៃដី L ដែលជាថ្នូរនឹងការបង់ប្រាក់ថ្លៃលក់ចំនួន ២០០.០០០ (ពីរសែន) ដុល្លារអាមេរិករបស់ខ្ញុំ ហើយចំពោះប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកជាប្រាក់កក់ដែលខ្ញុំបានប្រគល់ឲ្យមុននោះនឹងត្រូវយកមកគណនាធ្វើជាថ្លៃលក់ទិញមួយភាគ។

រយៈពេល ៣ សប្តាហ៍ក្រោយពីបានចុះកិច្ចសន្យានៃរឿងក្តីនេះដែលត្រូវនឹងថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ Y ស្រាប់តែយកប្រាក់ចំនួន ៤០.០០០ ( បួនម៉ឺន) ដុល្លារអាមេរិកមកដល់ផ្ទះរបស់ខ្ញុំ ហើយបានអះអាងតែម្នាក់ឯងថា "ខ្ញុំនឹងរំលាយកិច្ចសន្យានៃរឿងក្តីនេះដោយសារតែខ្ញុំរកបានអ្នកដែលទិញដី L ក្នុងតម្លៃខ្ពស់ជាងនេះ" ។ ខ្ញុំបានភ្ញាក់ផ្អើលនឹងរឿងនោះភ្លាមៗ ហើយដោយសារតែខ្ញុំមិនអាចទទួលយកនូវការអះអាងរបស់ Y បែបនោះទេ ទើបខ្ញុំមិនបានទទួលប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកដែល Y បានយកមក។

Y មិនព្រមប្រគល់ និង ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដី L ទេ ទោះបីជាថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០១៨ ដែលបានកំណត់នៅក្នុងកិច្ចសន្យានៃរឿងក្តីនេះបានកន្លងផុតក៏ដោយ។

ហេតុនេះហើយ ខ្ញុំទាមទារឲ្យ Y ប្រគល់ដី L និង ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយមូលហេតុនៃកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ។

- ការអះអាងរបស់ Y

ខ្ញុំទទួលស្គាល់ថា បានចុះកិច្ចសន្យានៃរឿងក្តីនេះជាមួយ X ហើយបានធ្វើលិខិតយថាភូត។

ប៉ុន្តែ រយៈពេល ២ សប្តាហ៍ក្រោយពីបានចុះកិច្ចសន្យានៃរឿងក្តីនេះ ដែលត្រូវនឹងថ្ងៃទី១៥ ខែ សីហា ឆ្នាំ ២០១៨ មានក្រុមហ៊ុនអចលនវត្ថុ Z ថា ចង់ទិញដី L ក្នុងតម្លៃ ៣00.000 (បីសែន) ដុល្លារអាមេរិក ហេតុនេះ ខ្ញុំបានសម្រេចចិត្តថា លក់ដី L ឲ្យទៅ Z ដោយធ្វើការរំលាយកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះជាមួយ X ។ ដូច្នេះហើយ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ ខ្ញុំបានទៅផ្ទះរបស់ X ហើយបានផ្តល់ប្រាក់ចំនួន ៥0.000 (ប្អូនម៉ឺន) ដុល្លារអាមេរិកដែលជាចំនួនទឹកប្រាក់ ២ ដងនៃប្រាក់ ២0.000 (ពីរម៉ឺន) ដុល្លារអាមេរិកជាប្រាក់កក់ដែលខ្ញុំបានទទួលរួចរាល់ ព្រមទាំងបានបង្ហាញឆន្ទៈថា រំលាយកិច្ចសន្យានៃរឿងក្តីនេះ។ ខ្ញុំមានអារម្មណ៍ថា សោកស្តាយចំពោះ X ប៉ុន្តែ កិច្ចសន្យានៃរឿងក្តីនេះ ត្រូវបានរំលាយប្រកបដោយសុពលភាព។

អាស្រ័យហេតុនេះ ខ្ញុំមិនអាចយល់ព្រមចំពោះការទាមទាររបស់ X ទេ។